អាត្លាស ខុបខូ គ្រុប

# ក្រមប្រតិបត្តិអាជីវកម្ម

*Sustainable Productivity*

# មាតិកា


អាត្លាស ខុបខូ គ្រុប 1
First in Mind—First in Choice® 2
តម្លៃស្នូល 3

ភាពទំនាក់ទំនង 4
សង្គម និង បរិស្ថាន 5
និយោជិត 6
អតិថិជន 7
ដៃគូអាជីវកម្ម 8
ម្ចាស់ភាគហ៊ុន 8

ភាពទទួលខុសត្រូវ 9
តម្លាភាព 9
ភាពសុចរិតនៃអាជីវកម្ម 10
អភិបាលកិច្ច 11
ការអនុវត្ត និង ការអនុលោមតាម 12


ពេលខ្លះ អាត្លាស ខុបខូ អេប៊ី និង បុត្រសម្ពន្ធរបស់ខ្លួន ត្រូវបានហៅថា អាត្លាស ខុបខូ គ្រុប, សម្ពន្ធក្រុមហ៊ុន ឬ អាត្លាស ខុបខូ។ ពេលខ្លះ អាត្លាស ខុបខូ អេប៊ី ក៏ត្រូវបានហៅត្រឹមតែជា អាត្លាស ខុបខូ ផងដែរ។

អាត្លាស ខុបខូ គ្រុប

# ក្រមប្រតិបត្តិអាជីវកម្ម

សេចក្ដីសង្ខេបនៅក្នុងក្រមប្រតិបត្តិអាជីវកម្មរបស់ អាត្លាស ខុបខូ គឺជាឯកសារស្ដីពីគោលការណ៍ផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងសីលធម៌អាជីវកម្ម ព្រមទាំងការប្រតិបត្តិចំពោះសង្គម និង បរិស្ថាន។ និយោជិត និង អ្នកគ្រប់គ្រងទាំងអស់ នៅក្នុងសម្ពន្ធក្រុមហ៊ុន ព្រមទាំងដៃគូអាជីវកម្ម ត្រូវតែរំពឹងថា គោរពយ៉ាងខ្ជាប់ខ្ជួនតាមគោលការណ៍ទាំងនេះ។

គោលការណ៍ណែនាំអំពីសីលធម៌ជាអន្តរជាតិដ៏ចម្បង ដែល អាត្លាស ខុបខូ គាំពារ រួមមាន៖

កម្រងសិទ្ធិមនុស្សជាអន្តរជាតិរបស់អង្គការសហប្រជាជាតិ www.un.org សេចក្ដីប្រកាសអំពីគោលការណ៍ និង សិទ្ធិជាមូលដ្ឋាននៅកន្លែងការងារ របស់អង្គការពលកម្មអន្តរជាតិ www.ilo.org កតិកាសញ្ញាជាសាកលរបស់អង្គការសហប្រជាជាតិ www.unglobalcompact.org គោលការណ៍ណែនាំរបស់ OECD សម្រាប់សហគ្រាសពហុជាតិ www.oecd.org

អាត្លាស ខុបខូ គឺជាសមាជិកនៃកតិកាសញ្ញាជាសាកលរបស់ UN ចាប់តាំងពីឆ្នាំ 2008។

ការរាយការណ៍អំពីនិរន្តរភាពរបស់ អាត្លាស ខុបខូ គោរពតាមគោលការណ៍ណែនាំរបស់ GRI—Global
Reporting Initiative (ការផ្ដួចផ្ដើមនៃការរាយការណ៍ជាសាកល)
www.globalreporting.org

# អាត្លាស ខុបខូ គ្រុប

អាត្លាស ខុបខូ គឺជាសម្ព័ន្ធក្រុមហ៊ុនឧស្សាហកម្មដែលមានកេរ្តិ៍ឈ្មោះនាំមុខគេនៅលើពិភពលោកខាងប្រព័ន្ធបង្ហាប់ ពង្រីក និង ព្យាបាលខ្យល់, គ្រឿងបរិក្ខារសំណង់ និង រ៉ែ, ឧបករណ៍ថាមពល ព្រមទាំងប្រព័ន្ធផ្គុំ។ វិសាលភាពប្រតិបត្តិការរបស់ក្រុមហ៊ុននៅទូទាំងពិភពលោកមានលើសពី 170 ប្រទេស។

សកម្មភាពអាជីវកម្មរបស់យើងត្រូវបានធ្វើឡើងតាមរយៈផ្នែកប្រតិបត្តិការដាច់ដោយឡែកពីគ្នាដែលសហការគ្នាជាសាកល។ អាត្លាស ខុបខូ គ្រុប បានរួបរួមគ្នា និង ធ្វើប្រតិបត្តិការស្របគ្នាតាមរយៈទស្សនវិស័យរួម អត្តសញ្ញាណរួម និង ការគោរពយ៉ាងខ្ជាប់ខ្ជួនតាមក្រមប្រតិបត្តិអាជីវកម្មរបស់ អាត្លាស ខុបខូ គ្រុប នេះ។



Ronnie Leten, ប្រធាន និង នាយប្រធានប្រតិបត្តិ ស្តុកហាម, ស៊ុយអែត, ថ្ងៃទី 1 កុម្ភៈ 2012



# First in Mind—First in Choice®

អាគ្លាស ខុបខូ គ្រុប មានទស្សនវិស័យមួយក្នុងការក្លាយជា និង នៅតែជា First in Mind—First in Choice® (គិតឃើញដំបូង—ជម្រើសដំបូង) របស់អតិថិជនខ្លួន អតិថិជនសក្តានុពល និង ភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។ ចំពោះយើងនេះមានន័យថា ភាពក្លាយជាអ្នកនាំមុខគេមួយ។ យើងគួរនាំមុខគេទាំងនៅក្នុងចំណែកនៃការគិត និង ទាំងនៅក្នុងចំណែកអាជីវកម្ម។ គេគួរមើលឃើញយើងថាជាអ្នកច្នៃប្រឌិតមួយដែលកំណត់ស្តង់ដាទូទៅ និង លើសពីក្តីរំពឹងទុកដ៏ខ្ពស់។

# តម្លៃស្នូល

តម្លៃស្នូលរបស់សម្ព័ន្ធក្រុមហ៊ុនគឺការទំនាក់ទំនង ការប្ដេជ្ញា និង ការច្នៃប្រឌិត បានបង្កើតអតីតកាលរបស់យើង បានស្ថាបនាបច្ចុប្បន្នភាពរបស់យើង ហើយនឹងជាមគ្គុទេសក៍ណែនាំអនាគតរបស់យើង។ តម្លៃស្នូលរបស់យើងបង្ហាញពីគុណសម្បត្តិខាងការប្រកួតប្រជែងរបស់សម្ព័ន្ធក្រុមហ៊ុន ហើយជួយយើងឲ្យរក្សាជំហរភាពជាអ្នកដឹកនាំរបស់យើង សូម្បីតែនៅក្នុងបរិស្ថានដែលមានការផ្លាស់ប្ដូរក៏ដោយ។

គុណលក្ខណៈដ៏សំខាន់របស់ អាត្លាស ខុបខូ គឺលទ្ធភាពមួយក្នុងការស្ដាប់ និង យល់ដឹងពីតម្រូវការចម្រុះរបស់អតិថិជនរបស់យើង និង ភាគីពាក់ព័ន្ធដទៃផ្សេងទៀត ហើយដោយរួមគ្នាជាមួយសមត្ថភាពរបស់យើង នឹងបង្កើតដំណោះស្រាយថ្មីៗ និង កាន់តែប្រសើរ ដោយផ្អែកលើអ្វី ដែលយើងបានរៀនពីដំណើរការអន្តរកម្មនេះ។

ការប្ដេជ្ញា មានន័យថា យើងបានចូលរួមពាក់ព័ន្ធទាំងស្រុងក្នុងការស្វែងរកដំណោះស្រាយដ៏ល្អបំផុត ដែលអ្នកអាចផ្ដល់ឲ្យ។ យើងប្ដេជ្ញាទាំងស្រុងចំពោះធនធានមនុស្សរបស់យើង និង ចំពោះការបន្ថែមតម្លៃដល់អាជីវកម្មរបស់អតិថិជនយើង ដូចដែលយើងធ្វើចំពោះគោលដៅ និង គោលបំណងផ្ទាល់ខ្លួនរបស់យើងដែរ។

យើងជឿជាក់ថា ជានិច្ចកាលតែងមានវិធីដ៏ល្អប្រសើរក្នុងការធ្វើអ្វីៗ។ ទស្សនៈច្នៃប្រឌិតនោះគឺជាផ្នែកដ៏សំខាន់បំផុតនៃអត្តសញ្ញាណរបស់ អាត្លាស ខុបខូ គឺជាផ្នែកដ៏សំខាន់បំផុតនៃវិធីប្រកបអាជីវកម្មរបស់យើង។ វាក៏ជាកម្លាំងជំរុញដែលបានធ្វើឲ្យយើងក្លាយជាអ្នកនាំមុខមួយនៅក្នុងឧស្សាហកម្មរបស់យើងផងដែរ។ ការច្នៃប្រឌិតគឺជាកត្តាជំរុញខ្ពស់បំផុតសម្រាប់លទ្ធភាពទទួលប្រាក់ចំណេញ និង ការលូតលាស់ ក្នុងរយៈពេលវែង។

តម្លៃស្នូលរបស់យើង—ការទំនាក់ទំនង ការប្ដេជ្ញា និង ការច្នៃប្រឌិត— ត្រូវបានឆ្លុះបញ្ចាំងក្នុងរបៀបដែលយើងទាក់ទិនជាមួយនឹងភាគីពាក់ព័ន្ធចម្បងៗរបស់យើង។ បន្ថែមលើនេះ ក្រុមហ៊ុនទាំងអស់នៅក្នុងសម្ព័ន្ធក្រុមហ៊ុន ត្រូវបានរំពឹងថា គោរពយ៉ាងខ្ជាប់ខ្ជួនតាមគោលការណ៍ដែលពាក់ព័ន្ធនឹងសីលធម៌អាជីវកម្ម ព្រមទាំងការប្រតិបត្តិចំពោះសង្គម និង បរិស្ថាន។

# ភាពទំនាក់ទំនង



# សង្គម និង បរិស្ថាន

យើងខំប្រឹងពុះពារឲ្យក្លាយជាក្រុមហ៊ុនដ៏ល្អ និង អាចទុកចិត្តបានមួយ ដោយអង្កេតមើលទស្សនៈ ព្រមទាំងច្បាប់របស់ប្រទេសដែលយើងធ្វើប្រតិបត្តិការ។

- យើងគាំពារសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិទាំងអស់ ហើយគោរពសិទ្ធិទាំងនោះ នៅក្នុងប្រតិបត្តិការរបស់សម្ពន្ធក្រុមហ៊ុន ទូទាំងពិភពលោក។
- យើងទទួលស្គាល់ថា ការប្តេជ្ញារបស់យើងចំពោះជោគជ័យខាងហិរញ្ញវត្ថុ ក៏ត្រូវតែយកមកគិតពិចារណាផងដែរចំពោះផលប៉ះពាល់ដល់សេដ្ឋកិច្ច បរិស្ថាន និង សង្គមដ៏ទូលំទូលាយ ពីប្រតិបត្តិការរបស់យើង។
- យើងជឿជាក់លើការប្រកបអាជីវកម្មក្នុងលក្ខណៈរក្សាបរិស្ថានសម្រាប់អ្នកជំនាន់ក្រោយ។ អាត្លាស ខុបខូ មានបំណងក្លាយជាអ្នកនាំមុខក្នុងឧស្សាហកម្ម ក្នុងកិច្ចការការពារបរិស្ថាន នៅក្នុងតំបន់ដែលប្រើប្រាស់ផលិតផល និង សេវារបស់យើង។ ជាផ្នែកមួយនៃកិច្ចខំប្រឹងប្រែងនេះ ផលិតផល និង ដំណើរការទាំងអស់ ត្រូវតែបានវាយតម្លៃដោយគិតលើទិដ្ឋភាពគុណភាព សុវត្ថិភាព សុខភាព និង បរិស្ថាន។ យើងមានបំណងឲ្យគ្រឿងចម្បងៗរបស់យើងទាំងអស់ទទួលវិញ្ញាបនបត្រ ISO 9001, ISO 14001 និង OHSAS 18001។
- អាត្លាស ខុបខូ លើកទឹកចិត្តការសិក្សា និង ការអភិវឌ្ឍ តាមរយៈកិច្ចសហប្រតិបត្តិការជាមួយសហគមន៍ក្នុងស្រុក និង ទទួលស្គាល់សារៈសំខាន់នៃទឹកសម្រាប់ទាំងអស់គ្នា ជាគម្រោងដ៏ចម្បងរបស់ខ្លួនក្នុងការចូលរួមជាមួយសហគមន៍។

# និយោជិត

យើងខំប្រឹងប្រែងឲ្យក្លាយជានិយោជកដែលទាំងនិយោជិតបច្ចុប្បន្ន និង និយោជិតសក្តានុពល ពេញចិត្ត។ គោលបំណងរបស់យើងគឺទាក់ទាញ អភិវឌ្ឍ និង រក្សាធនធានមនុស្សដែលមានគុណសម្បត្តិគ្រប់គ្រាន់ និង មានទឹកចិត្តមុះមុត នៅក្នុងបរិស្ថានប្រកបដោយវិជ្ជាជីវៈ។

- យើងមានបំណងផ្តល់នូវបរិស្ថានការងារដែលមានសុវត្ថិភាព និង សុខភាពល្អ នៅក្នុងប្រតិបត្តិការរបស់យើងទាំងអស់។
- យើងជឿជាក់លើការផ្តល់ឱកាសស្មើភាពគ្នា ភាពយុត្តិធម៌ និង ភាពចម្រុះ។ យើងរើស និង ដំឡើងតំណែង ដោយផ្អែកលើមូលដ្ឋានលក្ខណៈសម្បត្តិសម្រាប់ការងារដែលត្រូវធ្វើ ដោយមិនគិតពីពូជសាសន៍ សាសនា ភេទ អាយុ សញ្ជាតិ ពិការភាព ទំនោរផ្លូវភេទ សមាជិកភាពក្នុងសហជីព និង គំនិតនយោបាយឡើយ។
- យើងទទួលស្គាល់ថា និយោជិតមានសិទ្ធិក្នុងការជ្រើសរើសថាតើត្រូវទទួលការតំណាងដោយសហជីពកម្មករឬក៏អត់ ក្នុងគោលបំណងនៃការទាមទារជារួម។ គ្មានការរើសអើងណាមួយត្រូវធ្វើឡើងដោយផ្ទាល់ចំពោះនិយោជិតណាមួយឡើយ មិនថាសិទ្ធិដូចនោះត្រូវបានអនុវត្ត ឬក៏អត់ឡើយ។
- គ្មានកាលៈទេសៈណាមួយនឹងជំរុញឲ្យយើងជួល ឬ ប្រើពលកម្មដោយបង្ខំឡើយ នៅក្នុងប្រតិបត្តិការរបស់យើង។ យើងប្រឆាំងដាច់ខាតនឹងពលកម្មកុមារ ព្រមទាំងទម្រង់ផ្សេងទៀតនៃការកេងប្រវ័ញ្ចលើកុមារ។ យើងមិនជួលបុគ្គលណាម្នាក់ដែលមានអាយុក្រោម 15 ឆ្នាំឡើយ ហើយយើងនឹងសម្របតាមស្តង់ដាក្នុងស្រុកដែលបញ្ជាក់ពីអាយុខ្ពស់ជាងនេះ។
- យើងរំពឹងថានឹងរួមចំណែកដល់សម្ពន្ធក្រុមហ៊ុន ហើយការប្រតិបត្តិរបស់យើងនឹងទទួលផលតាមវិធីដ៏ត្រឹមត្រូវ។ បៀវត្សរ៍អប្បបរមាដែលច្បាប់បានកំណត់ នឹងជាស្តង់ដាអប្បបរមាជានិច្ច មិនមែនកម្រិតដែលបានឲ្យយោបល់ឡើយ។ ការវាយតម្លៃត្រូវធ្វើឡើងតាមមូលដ្ឋានប្រចាំឆ្នាំ។
- យើងបានទទួលការបណ្តុះបណ្តាល និង លទ្ធភាពអភិវឌ្ឍន៍ ជាបន្តបន្ទាប់ ដើម្បីការពារឱកាសរបស់យើង ក្នុងការលូតលាស់ជាមួយសម្ពន្ធក្រុមហ៊ុន។ គោលបំណងគឺថា និយោជិតម្នាក់ៗទទួលការអភិវឌ្ឍសមត្ថភាពដែលចាំបាច់ដើម្បីសម្រេចលទ្ធផលដ៏ល្អ។

- យើងទទួលការបណ្តឹះបណ្តាលអំពីសិទ្ធិមនុស្ស សុវត្ថិភាព អំពើពុករលួយ ផលប៉ះពាល់លើបរិស្ថាន និង ទិដ្ឋភាពដែលពាក់ព័ន្ធផ្សេងទៀតនៃប្រតិបត្តិការរបស់យើង។ តាមវិធីនេះ យើងធានាថា ការប្តេជ្ញារបស់យើងក្នុងការគោរព និង គាំពារសិទ្ធិទាំងនេះ ត្រូវបានចាត់ការទៅតាមនោះ។
- យើងលើកទឹកចិត្តឲ្យមានលំហូរព័ត៌មានឆ្លងកាត់ផ្នែក មុខងារ និង ព្រំដែនភូមិសាស្ត្រ ដើម្បីធ្វើឲ្យចំណេះដឹង និង បទពិសោធន៍ដែលមានទាំងអស់អាចប្រើប្រាស់បានពេញលេញ។

# អតិថិជន

យើងខំប្រឹងពុះពារក្លាយជាអ្នកផ្គត់ផ្គង់ដែលអតិថិជន និង អ្នកប្រើប្រាស់ចុងក្រោយ ក្នុងពេលបច្ចុប្បន្ន និង សក្តានុពល ពេញចិត្តដែលមានន័យថា យើងគួរទទួលបានអតិថិជនច្រើនបំផុត និង ចំណែកទីផ្សារធំបំផុត តាមដែលអាចទទួលបាន។

- យើងមានបំណងផ្តល់ផលិតផល និង សេវា ដែលមានគុណភាពខ្ពស់យ៉ាងជាប់លាប់ ដែលរួមចំណែកដល់ផលិតភាព និង វិបុលភាពរបស់អតិថិជនយើង។
- ផលិតផល និង សេវារបស់យើង ត្រូវបានអភិវឌ្ឍ ដោយមានបំណងបំពេញតាមតម្រូវការផលិតភាព គុណភាព មុខងារ សុវត្ថិភាព និង បរិស្ថាន របស់អតិថិជនយើង។
- យើងធ្វើប្រតិបត្តិការទូទាំងពិភពលោកជាមួយការប្តេជ្ញាក្នុងរយៈពេលវែងចំពោះអតិថិជននៅក្នុងប្រទេសនីមួយៗ និង ទីផ្សារដែលយើងបម្រើ ហើយយើងខំប្រឹងពុះពារបង្កើតទំនាក់ទំនងជិតដិតជាមួយអតិថិជនរបស់យើង ដើម្បីអាចបំពេញក្តីរំពឹងទុក និង ឲ្យលើសក្តីរំពឹងទុករបស់ពួកគេ ជាបន្តបន្ទាប់។

# ដៃគូអាជីវកម្ម

យើងខំប្រឹងពុំពារឲ្យក្លាយជាគូកនដ៏ល្អបំផុតសម្រាប់ដៃគូអាជីវកម្មរបស់យើង ដូចជា អ្នកផ្គត់ផ្គង់ អ្នកជាប់កិច្ចសន្យាបន្ត ដៃគូរកស៊ីរួមគ្នា ភ្នាក់ងារ និង អ្នកចែកចាយ ហើយឲ្យក្លាយជាដៃគូមួយដែលពួកគេកំណត់ជាអាទិភាព។

- យើងស្វែងរក វាយតម្លៃ និង ជ្រើសរើសដៃគូអាជីវកម្មដោយមិនលម្អៀង តាមមូលដ្ឋាននៃកត្តាគោលដៅ រួមទាំងផលិតភាព គុណភាព ភាពចម្រុះ តម្លៃ និង ភាពទុកចិត្ត ព្រមទាំងការប្ដេជ្ញាចំពោះបរិស្ថាន សង្គម និង ការអភិវឌ្ឍ។
- យើងធ្វើឲ្យពួកគេដឹងពីការប្ដេជ្ញារបស់យើង ហើយរំពឹងថា ពួកគេគោរពយ៉ាងខ្ជាប់ខ្ជួនតាមគោលការណ៍របស់យើង។

# ម្ចាស់ភាគហ៊ុន

យើងខំប្រឹងពុះពារឲ្យក្លាយជាក្រុមហ៊ុនដែលម្ចាស់ភាគហ៊ុនចូលចិត្តវិនិយោគជាមួយ ហើយយើងមានបំណងបង្កើត និង បង្កើនជាបន្តបន្ទាប់ នូវតម្លៃរបស់ម្ចាស់ភាគហ៊ុន។

- យើងធ្វើអ្វីៗដែលយើងអាច ដើម្បីធានាឲ្យបាននូវការអភិវឌ្ឍប្រកបដោយភាពចំណេញជានិរន្ត ជាមួយនឹងការប្រើប្រាស់ធនធានប្រកបដោយការទទួលខុសត្រូវ៖ មនុស្ស ធម្មជាតិ និង មូលធន។
- យើងមានបំណងផ្ដល់ផលពីការវិនិយោគក្នុងរយៈពេលវែង លើសមធ្យមភាគនៃឧស្សាហកម្ម តាមរយៈការផ្ដល់ផលិតផល និង សេវាប្រកបដោយការច្នៃប្រឌិត និង ប្រកួតប្រជែង ដល់អតិថិជនរបស់យើង ដើម្បីទទួលផលិតភាពជានិរន្ត។

# ភាពទទួលខុសត្រូវ

## តម្លាភាព

នៅក្នុងការទំនាក់ទំនងរបស់យើងទាំងអស់ ទាំងសំណេរ និង ការនិយាយ យើងប្តេជ្ញាឲ្យមានលក្ខណៈបើកចំហរ ពិត និង សុក្រឹត នៅក្នុងដែនកំណត់នៃការរក្សាភាពសម្ងាត់អាជីវកម្ម។ យើងផ្តល់ព័ត៌មានដែលអាចទុកចិត្តបាន និង ព័ត៌មានពាក់ព័ន្ធអំពីសកម្មភាពរបស់យើង ឲ្យបានទាន់ពេលវេលា ជាប្រចាំ។ យើងចាត់ទុកការទំនាក់ទំនងថាមានសារៈសំខាន់ណាស់ ដូច្នេះហើយទើបមានអាកប្បកិរិយាវិជ្ជមានទៅរកការសន្ទនាលក្ខណៈស្ថាបនាជាមួយភាគីពាក់ព័ន្ធនឹងយើងទាំងអស់។

អាត្លាស ខុបខូ បានបង្កើតស្តង់ដាដ៏ខ្ពស់ក្នុងការរាយការណ៍ ដែលនិយោជិតគ្រប់រូបដែលពាក់ព័ន្ធនឹងការកត់ត្រា ការដំណើរការ និង ការរាយការណ៍ព័ត៌មាន ត្រូវបានរំពឹងថាការពារភាពសម្ងាត់ សុពលភាព និង ភាពត្រឹមត្រូវនៃព័ត៌មាននោះ។

លទ្ធផលហិរញ្ញវត្ថុត្រូវបានបោះពុម្ពផ្សាយក្នុងរបាយការណ៍ប្រចាំឆ្នាំ និង ប្រចាំត្រីមាស។ ការប្រតិបត្តិខាងសេដ្ឋកិច្ច បរិស្ថាន និង សង្គម ត្រូវបានបោះពុម្ពផ្សាយក្នុងរបាយការណ៍និរន្តរភាពប្រចាំឆ្នាំ។

ឯកសារដែលបានបោះពុម្ពផ្សាយអាចចូលមើលតាមរយៈវិបសៃរបស់ អាត្លាស ខុបខូ www.atlascopco.com ដែលផ្តល់នូវព័ត៌មានបន្ថែមដ៏ទូលំទូលាយអំពីម៉ាក និង ប្រតិបត្តិការរបស់យើង។

# ភាពសុចរិតនៃអាជីវកម្ម

គ្រប់កន្លែងដែលយើងធ្វើប្រតិបត្តិការ កេរ្តិ៍ឈ្មោះរបស់យើងគឺជាទ្រព្យដ៏មានតម្លៃបំផុត ហើយវាត្រូវបានកំណត់ដោយរបៀបដែលយើងធ្វើសកម្មភាព។ យើងគួរជៀសវាងសកម្មភាពទាំងឡាយណាដែលបង្កអន្តរាយដល់ការគោរពចំពោះសម្ពន្ធក្រុមហ៊ុន។

- យើងមានស្តង់ដាដ៏ខ្ពស់សម្រាប់សីលធម៌អាជីវកម្ម និង សីលធម៌ផ្ទាល់ខ្លួន។ យើងគោរពយ៉ាងខ្ជាប់ខ្ជួនចំពោះគោលការណ៍ផ្ទៃក្នុងរបស់យើង ព្រមទាំងគោរពតាមច្បាប់ និង បទបញ្ញាជាធរមានទាំងអស់យ៉ាងជាក់លាក់ នៅក្នុងប្រទេសដែលយើងធ្វើប្រតិបត្តិការ។
- យើងមិនអត់ឱនដល់សំណូក និង អំពើពុករលួយឡើយ រួមទាំងការបង់ប្រាក់សម្រួលការ។ ចំណាត់ការម៉ឺងម៉ាត់នឹងធ្វើឡើងចំពោះការបំពានទាំងឡាយ។
- យើងប្តេជ្ញាចំពោះភាពស្មោះត្រង់នៅគ្រប់ស្ថានភាពទាំងអស់ ហើយយើងជៀសវាងពីការមានទំនាស់ផលប្រយោជន៍ផ្ទាល់ខ្លួនជាមួយផលប្រយោជន៍របស់សម្ពន្ធក្រុមហ៊ុន។
- យើងគាំពារ និង ខំប្រឹងពុំពារធ្វើការប្រកួតប្រជែងដោយស្មោះត្រង់ ដូច្នេះហើយ នឹងបដិសេធក្នុងការពិភាក្សា ឬ ការធ្វើកិច្ចព្រមព្រៀងជាមួយគូប្រកួតប្រជែង ពាក់ព័ន្ធនឹងការកំណត់តម្លៃ ការចែករំលែកទីផ្សារ ឬ សកម្មភាពស្រដៀងនេះដទៃផ្សេងទៀត។
- អំណោយ ឬ បដិសណ្ឋារកិច្ចការងារ អាចផ្តល់ជូន ឬ អាចទទួល តែក្នុងករណីស្របតាមការអនុវត្តស្របច្បាប់ និង ទម្លាប់អាជីវកម្មនៅក្នុងស្រុកប៉ុណ្ណោះ។
- យើងគោរពទ្រព្យរបស់ក្រុមហ៊ុន ហើយការពារទ្រព្យរូបីយ និង អរូបីយទាំងអស់របស់ក្រុមហ៊ុន កុំឲ្យបាត់បង់ មានគេលួច និង ប្រើប្រាស់ខុស។
- ការបញ្ចុះបញ្ចូលត្រូវបានធ្វើឡើងជាចម្បងតាមរយៈការតំណាង ឬ ក្នុងជំនួញ និង អង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត។
- សម្ពន្ធក្រុមហ៊ុនមិនប្រកាន់ជំហរនយោបាយណាមួយឡើយ។ ដូច្នេះ យើងមិនប្រើមូលនិធិ ឬ ទ្រព្យរបស់សម្ពន្ធក្រុមហ៊ុន ដើម្បីគាំពារយុទ្ធនាការ ឬ បេក្ខជននយោបាយ ឬក៏ផ្តល់សេវាដល់សកម្មភាពនយោបាយឡើយ។




# អភិបាលកិច្ច

ក្រុមប្រឹក្សាភិបាលគឺជាម្ចាស់កម្មសិទ្ធិនៃក្រុមនេះ និង ជាអ្នកត្រួតពិនិត្យលើមាតិកា និង ការអនុលោមតាមក្រុមនេះ ហើយនឹងផ្តល់ការយល់ព្រមចំពោះយុទ្ធសាស្ត្ររបស់សម្ពន្ធក្រុមហ៊ុនជាទូទៅ ព្រមទាំងធ្វើការចាត់ចែង។ លើកលែងតែចំពោះបុគ្គលម្នាក់ប៉ុណ្ណោះគឺ ប្រធាន និង CEO ក្រុមប្រឹក្សាភិបាលមានសមាសភាពដែលសុទ្ធតែជានាយកមិនប្រតិបត្តិប៉ុណ្ណោះ។ ក្រុមប្រឹក្សាភិបាលមានគណៈកម្មាធិការចំនួនពីរ៖ គណៈកម្មាធិការសវនកម្ម និង គណៈកម្មាធិការលាភការ។

ប្រធាន និង CEO ទទួលខុសត្រូវចំពោះមុខក្រុមប្រឹក្សាភិបាល សម្រាប់ប្រតិបត្តិការប្រចាំថ្ងៃរបស់សម្ពន្ធក្រុមហ៊ុន។

ថ្នាក់គ្រប់គ្រងប្រតិបត្តិរបស់សម្ពន្ធក្រុមហ៊ុនទទួលខុសត្រូវចំពោះការបង្កើត និង តាមដានយុទ្ធសាស្ត្រ គោលដៅ និង គោលការណ៍របស់សម្ពន្ធក្រុមហ៊ុន រួមទាំងការប្រតិបត្តិខាងហិរញ្ញវត្ថុ ការប្រតិបត្តិចំពោះសង្គម និង បរិស្ថាន ក្រោមការដឹកនាំរបស់ប្រធាន និង CEO។

# ការអនុវត្ត និង ការអនុលោមតាម

ក្រមប្រតិបត្តិអាជីវកម្មនេះសង្ខេបពីគោលការណ៍ទូទៅចំពោះក្រុមហ៊ុនទាំងអស់នៅក្នុងសម្ព័ន្ធក្រុមហ៊ុន។ អាកប្បកិរិយារបស់យើងត្រូវបានណែនាំដោយគោលការណ៍ផ្ទៃក្នុងទាំងនេះ ដែលជួយយើងឲ្យបង្កើនតម្លៃរបស់សម្ព័ន្ធក្រុមហ៊ុន។

គោលការណ៍ទាំងនេះ អមជាមួយគោលការណ៍ មគ្គុទេសក៍ណែនាំ និង សេចក្តីណែនាំផ្សេងទៀត ត្រូវបានប្រមូលទុកក្នុង The Way We Do Things (វិធីដែលយើងធ្វើអ្វីៗ) ដែលជាមូលដ្ឋានទិន្នន័យផ្ទៃក្នុង ដែលអាចឲ្យនិយោជិតទាំអស់ចូលមើលតាមរយៈអ៊ីនត្រាណិតរបស់ អាត្លាស ខុបខូ។

វាគឺជាការទទួលខុសត្រូវរបស់និយោជិតម្នាក់ៗក្នុងការយល់ដឹងថ្មីកជាមួយខ្លឹមសារព័ត៌មាននៃ The Way We Do Things (វិធីដែលយើងធ្វើអ្វីៗ) ហើយត្រូវគោរពតាមឲ្យបានខ្ជាប់ខ្ជួន។ ការបណ្តុះបណ្តាលសមស្របត្រូវបានផ្តល់ជូនតាមរយៈកម្មវិធី Circles របស់សម្ព័ន្ធក្រុមហ៊ុន ដែលចាំបាច់សម្រាប់និយោជិតថ្មីៗគ្រប់រូប។ យើងជូនដំណឹងដល់ភាគីពាក់ព័ន្ធសំខាន់ៗអំពីក្រមប្រតិបត្តិអាជីវកម្មរបស់យើង។

ដោយផ្អែកលើគោលការណ៍ដែលបានពណ៌នាក្នុង The Way We Do Things (វិធីដែលយើងធ្វើអ្វីៗ) អង្គភាពប្រតិបត្តិការនឹងរៀបចំយុទ្ធសាស្ត្រ និង គម្រោងអនុវត្ត។ អ្នកគ្រប់គ្រងគ្រប់រូបត្រូវទទួលខុសត្រូវចំពោះការពង្រឹង និង ការតាមដានការអនុលោមតាមជារៀងរាល់ថ្ងៃ។

នីតិវិធីតាមដានត្រូវបានបង្កើតសម្រាប់គោលការណ៍នីមួយៗ។ សូចនករបង្ហាញពីការប្រតិបត្តិចំពោះសង្គម និង បរិស្ថាន ត្រូវបានរាយការណ៍ និង តាមដាន នៅកម្រិតសម្ព័ន្ធក្រុមហ៊ុន។ ការវាយតម្លៃហានិភ័យពាក់ព័ន្ធនឹងភាគីពាក់ព័ន្ធសំខាន់ៗរបស់យើង ទាក់ទិននឹងច្បាប់ ព្រមទាំងការប្រតិបត្តិចំពោះសង្គម និង បរិស្ថាន ត្រូវបានរាយការណ៍ក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល។

ដើម្បីការពារការអនុវត្ត សវនកម្មផ្ទៃក្នុងត្រូវបានធ្វើឡើងនៅនឹងកន្លែង នៅក្នុងក្រុមហ៊ុនទាំងឡាយរបស់យើង។

ចំពោះការបំពានដែលបានដឹងលើក្រមប្រតិបត្តិអាជីវកម្មនេះ គេគួរទាក់ទងអ្នកគ្រប់គ្រងផ្ទាល់ ឬ អ្នកគ្រប់គ្រងរបស់គេ ដំបូងគេ។ បើគ្មានចំណាត់ការណាមួយទេ របាយការណ៍នោះគួរផ្ញើទៅខ្សែជំនួយខាងសីលធម៌របស់សម្ព័ន្ធក្រុមហ៊ុន hotline@se.atlascopco.com។ ក្រុមប្រឹក្សាច្បាប់របស់សម្ព័ន្ធក្រុមហ៊ុនជាអ្នកទទួលរបាយការណ៍ទាំងនេះ និង ធានាពីភាពអនាមិក ព្រមទាំងភាពសម្ងាត់របស់អ្នករាយការណ៍។ ការបំពានត្រូវបានថ្លែងភ្លាមៗ ហើយអាចទទួលចំណាត់ការពិន័យ រួមទាំងការបញ្ចប់ការជួលឲ្យធ្វើការងារ។

# ទំនាក់ទំនង

អាត្លាស ខុបខូ អេប៊ី ខប់ផូរេត ខំម្មូនីខេសុន
SE-105 23 ស្តុកហាម, ស៊ុយអែត ទូរសព្ទ៖ +46-8-743 8000

ព័ត៌មានអំពីនិរន្តរភាព៖ cr@se.atlascopco.com ទំនាក់ទំនងវិនិយោគិន៖
ir@se.atlascopco.com ខ្សែជំនួយខាងសីលធម៌៖
hotline@se.atlascopco.com

ចំពោះឯកសារបោះពុម្ពផ្សាយជាទ្រង់ទ្រាយអេឡិចត្រូនិក និង ព័ត៌មានផ្សេងៗ
អំពី អាត្លាស ខុបខូ គ្រុប សូមចូលទៅ៖ www.atlascopco.com
របាយការណ៍ប្រចាំឆ្នាំ របាយការណ៍ប្រចាំត្រីមាស របាយការណ៍និរន្តរភាព
បណ្ណសារ (ទស្សនាវដ្តីរបស់ក្រុមហ៊ុនប្រចាំឆ្នាំ)

# Sustainable Productivity

យើងខ្ញុំទទួលយកការទទួលខុសត្រូវចំពោះអថិតិជនរបស់យើង ចំពោះបរិស្ថាន និងប្រជាពលរដ្ឋដែលនៅជុំវិញយើង។ យើងខ្ញុំរៀបចំការទទួលយកការអនុវត្តន៍ ចំពោះការធ្វើតេស្តអំពីពេលវេលា។ ហើយនេះជាអ្វីដែលយើងខ្ញុំហៅថា - បរិមាណផលិតកម្មប្រកបដោយនិរន្តភាព

www.atlascopco.com

Atlas Copco

9850 9086 88
©Atlas Copco AB, Sweden 2012, Edition 6
Production: Brand Studio, 2015. Print: nnn (xxx)